# រកការជួយដោះស្រាយបញ្ហា នៃជនអន្តោប្រវេសន៍



**អ្នក**អន្តោប្រវេសន៍នៅស្រុកសាន់តាក្លារ៉ា ជាញឹកញាប់គេត្រូវការជួប ជាមួយមេធាវីសំរាប់អន្តោប្រវេស៍ ឬអ្នកដែលចេះខាងច្បាប់ សំរាប់ជួយគេឲ្យយល់ពីច្បាប់ស្មុកស្មាញ និងការតម្រូវផ្សេងៗ ពីច្បាប់អន្តោប្រវេសន៍។ នៅខាងក្រោមនេះគឺជាសំនួរ និងចម្លើយអំពីអ្នកចេះច្បាប់ អន្តោប្រវេសន៍ ហើយតើធ្វើម្តេច រកការជួយច្បាប់ឲ្យបាន ប្រសើ សំរាប់អ្នកនិងគ្រួសារ។

## តើអ្វីទៅ ជាមេធាវីនៅស្រុកអាមេរិក?

មេធាវីនៅស្រុកអាមេរិក គឺជាមនុស្សម្នាក់ដែលបានរៀននៅថ្នាក់មហាវិទ្យាល័យច្បាប់ហើយបានទទួលសញ្ញាបត្រជា Juris Doctor (J.D.)។ ដើម្បីនឹងអាចធ្វើការសំរាប់ច្បាប់នៅក្នុងស្រុកអាមេរិក មេធាវីត្រូវតែជាសមាជិក ក្នុង State Bar Association និងត្រូវតែប្រឡងជាប់ ការប្រឡងដែលដាក់ឲ្យដោយ State Bar Association។

មេធាវីពេញច្បាប់អាច :

- ផ្តល់យោបល់អំពីច្បាប់ឲ្យទៅអ្នកដែលត្រូវរកការជួយ និង
- ធ្វើជាតំណាងអ្នកនោះក្នុងតុលាការ

តាមធម្មតាមេធាវី មានចំណេះពិតប្រាកដ នៅក្នុងតែភាគបន្តិចនៃច្បាប់។ ឧទាហរណ៍ ដូចជាមេធាវីខ្លះ អាចជួយបានចំពោះតែ អ្នកណាមួយដែលមានបញ្ហាក្នុងបទឧក្រិដ្ឋ ហើយមិនអាចដឹងអំពីច្បាប់អន្តោប្រវេសន៍ទេ។

## តើមានតែមេធាវីឬទេ ដែលជាអ្នកអាចជួយខ្ញុំបានក្នុងរឿងច្បាប់ទម្លាប់នៃអន្តោប្រវេសន៍?

មិនមែនទេ អ្នកមិនមែនមេធាវី ក៏អាចជួយអ្នកក្នុងរឿងខ្លះៗ។ អ្នកមិនមែនមេធាវី ក៏អាចចេះច្បាប់ និងការយល់ដឹង មានការពិសោធន៍សំរាប់ប្រើក្នុងច្បាប់អន្តោប្រវេសន៍បានដែរ។

អ្នកមិនមែនមេធាវី អាចជួយអ្នកបានដោយ:

- ធ្វើការជាមួយក្រសួង ដែលមានចំណេះទទួលស្គាល់ដោយសារ Board of Immigration Appeals (BIA) នៅរដ្ឋ Washington, D.C. ។
- ជាអ្នកធ្វើការដោយឡែក ហើយបានទទួលស្គាល់ជាតំ ណាង Board of Immigration Appeals (BIA) នៅរដ្ឋ Washington, D.C. ។
- អ្នកទីប្រឹក្សា របស់ជនអន្តោប្រវេសន៍ អាចជួយអ្នកបានតែ មិនអាចឲ្យយោបល់ ដឹកនាំអ្នកអំពីច្បាប់ទេ។ មុខងារគេគ្រាន់តែប្រាប់ពីច្បាប់ឲ្យអ្នកបានដឹងប៉ុណ្ណោះ។

## តើមានក្រសួងអ្នកចេះច្បាប់ នៅស្រុកសាន់តាក្លារ៉ា ឬទេ?

មានក្រសួងតែបីទេនៅ ស្រុកសាន់តាក្លារ៉ា គឺ : Catholic Charities, ទីមន្ទលសំរាប់រៀនបាត់ហ្វឹកហ្វឺនខាង ធ្វើការងារ the Center for Employment Training (CET), និង ក្រុមគណះកម្មាធិការ សង្គ្រោះអន្តរជាតិ the International Rescue Committee.

## មិត្តភក្តិខ្ញុំប្រាប់ថាមាន **notary** ឬ **"notario"** ដែលអាចធ្វើការ ឲ្យបានយ៉ាងថោក ហើយបានយ៉ាងរហ័ស។

អ្នកទីប្រឹក្សា របស់ជនអន្តោប្រវេសន៍ ឬហៅថា Notaries or Notario) ដែលគ្មានការរៀនច្បាប់ ឬទាក់ទង នឹងមេធាវី ឬក៏មិនបានទទួលស្គាល់ ជាអ្នកតំណាងខាងលើ អាចជួយអ្នកឲ្យបំពេញក្រដាសស្នាមបាន ប៉ុន្តែមិនអាចឲ្យយោបល់អំពីច្បាប់ទេ ដោយហេតុនេះហើយគេប្រហែលជា មិនអាចដោះស្រាយ សំនួរបញ្ហា ឬការបារម្ភ ដោយសារគេគ្មានការរៀនអីច្បាប់ត្រឹមត្រូវ។



**ត្រូវការពត៌មានថែមទៀត?** សូមទាក់ទងតាមខ្សែទូរស័ព្ទ SIREN's Immigrant Assistance & Information Line សំរាប់កម្មវិធីប្តូរថ្មី និងសំនួរជាទូទៅ។ ទូរស័ព្ទទាំងអស់មានបើក ពីថ្ងៃ ចន្ទ-សុក្រ ម៉ោង ១០ព្រឹក-៤ល្ងាច ហើយជាពីរភាសា អង់គ្លេសនិងភាសាដូចតទៅ :
អេស្ប៉ាញ៉ុល- (408) 286-1698 វៀតណាម- (408) 286-1448 **Farsi**- (408) 286-5680 x108 និងចិន- (408) 286-5680 x109

## ការពារខ្លួនឯង!

## ត្រូវដឹងអំពី notaries ឬ "notarios" ដែលជាអ្នកចេះប៉ិនបន្លំ ហើយលួចលុយអ្នក

**មិនថានរណា** ដែលជួយអ្នកក្នុងកិច្ចការច្បាប់អន្តោប្រវេសន៍ទេ អ្នកត្រូវតែចាំជានិច្ចថា :

- សួរយក ក្រដាសកូបពី អំពីកិច្ចសន្យាបំរើ
- ត្រូវទុក សំបុត្រស្នាមដើមកំណើត (មិនជាកូបពីទេ ដូចជាសំបុត្របញ្ជាក់កំណើត...)
- ត្រូវតែសួរបញ្ជាក់អំពី "business bureau" តើមានអ្នកណាប្តឹងពីអ្នកនោះទេ?
- និយាយជាមួយអង្គារសហាគម អំពីការសំរេចចិត្តផ្លូវណារបស់អ្នក។

## តើ INS ធ្វើការដូចម្តេច?

The Immigration and Naturalization Service គឺជាក្រសួងដែលជួយប្រយោជន៍ ដល់ជនអន្តោប្រវេសន៍ ហើយក៏អនុវត្តិច្បាប់ដែរ ព្រមទាំងមើលបញ្ជូនទៅស្រុកវិញ និងការពារនៅទល់ដែនផង។ គេមានការិយាល័យខុសៗគ្នា។ The INS ការិយាល័យនៅស្រុកនេះមាននៅ San Francisco ថ្វីបើគេមាន INS ការិយាល័យមួយនៅ San Jose ក៏ដោយ។ The INS ការិយាល័យនៅ San Jose ធ្វើការសំរាប់ស្រុក ចំនួន ៤: Santa Clara, Santa Cruz, Monterey, and San Benito.

ជាការទូរទៅ មានការពិបាកណាស់ នឹងនិយាយជាមួយនរណាមួយតាមទូរស័ព្ទ ទៅ INS ហើយបើចង់ឲ្យបានល្អ សូមទៅជួបនឹងមនុស្សផ្ទាល់។ ក៏ប៉ុន្តែអ្នកដែលគេត្រូវបញ្ជូនត្រឡប់ទៅស្រុកវិញ អាចនឹងគេបញ្ជូនបានបើ គេទៅកន្លែង INS វាមានការសុខជាងនឹងទៅសុំយកយោបល់ពីអ្នកច្បាប់អន្តោប្រវេសន៍ ជាជាងនឹងទៅជួបនៅកន្លែង **INS** ផ្ទាល់។

## តើខ្ញុំអាចនាំ សមាជិកគ្រួសារខ្ញុំ ចូលស្រុកយ៉ាងដូចម្តេច?

ដើម្បីនឹងអាចនាំសមាជិកគ្រួសារខឲ្យចូលស្រុកបាន អ្នកត្រូវតែជា :

ក) ប្រជាជនជាតិអចិន្ត្រ័យ (ជាអ្នកកាន់នូវកាតពណ៌បៃតង)

ខ) មានសញ្ជាតិជាអាមេរិកកាំង

មនុស្សដែលមានកាតបៃតង អាចនាំចូលនូវ ប្តី ឬ ប្រពន្ធ និងកូនដែលមិនទាន់រៀបការ។

អ្នកដែលមានសញ្ជាតិអាមេរិកកាំង អាចនាំមកចូលរស់នៅ អ្នកដែលត្រូវជា ប្តីឬប្រពន្ធគេ កូនដែលរៀបការ ឬ មិនទាន់រៀបការ ឪពុកម្តាយ និងបងប្អូនស្រីប្រុស។

អ្នកដែលចុះសុំយក អ្នកមានច្បាប់នៅ ឬមានសញ្ជាត្តិអាមេរិកាំង ត្រូវតែដាក់ពាក្យសុំ ដើម្បីយកសមាជិក គ្រួសារដែលកំពង់ រស់នៅក្នុងស្រុកកំណើតខ្លួននៅឡើយ។ ដោយសារតែច្បាប់ថ្មីៗ នេះមានចាប់ប្រើហើយ ពេលសៀវភៅនេះបានសរសេរ ការយកគ្រួសារឲ្យបានរស់នៅ ស្រុកអាមេរិក ហើយគ្រួសារនេះសព្វថ្ងៃចូលមកក្នុងស្រុករួចហើយ ដោយគ្មានការអនុញ្ញាតពី សហរដ្ឋអាមេរិក ឬ ក៏គ្មានវីហ្សា អ្វីទេនោះ វាអាចនឹងទៅជាមានលទ្ធផលមិនល្អ ចំពោះការធានារបស់អ្នក។ សូមទាក់ទងនឹងអ្នកជំនាញការខាងអន្តោប្រវេសន៍ មុននឹងបំពេញក្រដាស់ដាក់សុំឲ្យ សមាជិកគ្រួសារខាងលើនេះ។

សព្វថ្ងៃនេះ ដើម្បីនឹងចេញកាតពណ៌បៃតង ឲ្យជនអន្តោប្រវេសន៍នោះ គឺគេរើស តំរ៉ូវទៅតាម ប្រភេទ តាមពួក និងការចូលចិត្ត។ ដោយហេតុនេះ ចំនួនពេលដែលត្រូវសុំបានចូលមកនៅស្រុកអាមេរិក សមាជិកគ្រួសារ អាចបានមកឆាប់ ឬ ក៏យូរដល់ ២០ ឆ្នាំ ទៅតាមសភាពការអ្នក ទំនាក់ទំនង ជាមួយសមាជិកគ្រួសារនោះ និងដោយសារប្រទេសកំណើត អ្នកផង។



ត្រូវការពត៌មានថែមទៀត? សូមទាក់ទងតាមខ្សែទូរស័ព្ទ SIREN's Immigrant Assistance & Information Line សំរាប់កម្មវិធីថ្មីៗ និងសំនួរជាទូទៅ។ ទូរស័ព្ទទាំងអស់មានបើក ពីថ្ងៃ ចន្ទ-សុក្រ ម៉ោង ១០ព្រឹក-៤ល្ងាច ហើយជាពីរភាសា អង់គ្លេសនិងភាសាដូចតទៅ :
អេស្ប៉ាញ៉ុល- (408) 286-1698 វៀតណាម- (408) 286-1448 **Farsi**- (408) 286-5680 x108 និងចិន- (408) 286-5680 x109

**Asian Law Alliance**
184 East Jackson Street, San, Jose, CA 95112
Tel: (408) 287-9710
Website: www.asianlawalliance-ala.org

ភាសា: អេស្ប៉ាញ៉ូល អង់គ្លេស វៀតណាម លាវ ចិន ជប៉ុន។
ការបំរើ: ជួយធ្វើ N-400 កន្លែងជួយធ្វើបំពេញក្រដាសស្នាម អន្តោប្រវេសន៍ ជារៀងរាល់ខែ និងសុំ VAWA។

**Catholic Charities of Santa Clara County – San Jose Office**
2625 Zanker Road Suite 201, San, Jose, CA 95134-2107
Tel: (408) 944-0691
ភាសា: អេស្ប៉ាញ៉ូល អង់គ្លេស Portuguese, Tagalog និងវៀតណាម។
ការបំរើ: ការបំរើអំពីច្បាប់អន្តោប្រវេសន៍។ របៀបចូលសញ្ជាតិ។

Gilroy: 7950 Church Street, Gilroy, CA 95020
Tel: (408) 842-4808
Website: www.ccsj.org

ភាសា: អេស្ប៉ាញ៉ូល
ការបំរើ: ការបំរើអំពីច្បាប់អន្តោប្រវេសន៍។

**Center for Employment Training (CET)**
701 Vine Street, San Jose, CA 95110
Tel: (408) 534-5451
Website: www.cet2000.org

ភាសា: អេស្ប៉ាញ៉ូល និងការបកប្រែភាសា។
ការបំរើ: ពន្យល់ឲ្យយោបល់ នូវច្បាប់អន្តោប្រវេសន៍ ជាអ្នកដំណាងសុំវិហប្បាឲ្យគ្រួសារ ជួយក្នុងការសរសេរស្បេត់ស្បែរតាមក្រដាសស្នាម ការធ្វើបានត្រូវច្បាប់ក្នុងភាពក្រដាសស្នាម consular processing អនុញ្ញាតិច្បាប់ឲ្យធ្វើការ ពត៌មានផ្សេងៗ និងការបញ្ជូនបន្តរ ធ្វើក្រដាសស្នាមច្បាប់និងការបកប្រែភាសា ការចូលសញ្ជាតិ ការសិក្សាជាទូទៅ និងការបំរើផ្សេងទៀត ទៅតាមករណីយនិមួយៗ។

**East San Jose Community Law Center**
1765 Alum Rock Avenue, San Jose, CA 95126
Tel: (408) 254-0444
Website: www.scu.ed/law/ESJCLC

ភាសា: មានការបកប្រែជូនចំពោះភាសារជាច្រើនទាំងអស់។
ការបំរើ: ការបំរើអំពីច្បាប់អន្តោប្រវេសន៍ ដូចជា VAWA អ្នកទោសននោបាយ ការពារមិនឲ្យបញ្ជូនទៅស្រុកវិញ និងរឿងរ៉ាវច្បាប់ផ្សេងៗទៀត។ ហើយមានជួយថែមទៀតនូវ កន្លែងសំរាប់ជួយក្នុងសិទ្ធនៃការងារ សំណងជម្ងឺចិត្តដល់អ្នកធ្វើការ និងការជួយច្បាប់ដល់អ្នកធ្វើពាណិជ្ជកម្មតូចៗ។

**International Rescue Committee**
90 East Gish Road, San, Jose, CA 95112
Tel: (408) 453-3536
Website: www.@theirc.org

ភាសា: បារាំង លាវ Persian, Serbo-Croatian ថៃ វៀតណាម Oromo, Somali, Amharic, Assyrian, Arabic ។
ការបំរើ: ការបំរើអំពីច្បាប់អន្តោប្រវេសន៍ ពន្យល់ឲ្យយោបល់ផ្លូវច្បាប់ ការសុំ វិហប្បាឲ្យបងប្អូន ការធ្វើបានត្រូវច្បាប់ក្នុងភាពក្រដាស់ស្នាម consular processing អនុញ្ញាតិច្បាប់ឲ្យធ្វើការ ជួយក្នុងការសរសេរស្បេត់ស្បែរតាមក្រដាសស្នាម ការលប់ចោលនូវលក្ខណៈដើម្បីឲ្យអ្នករស់ក្នុងស្រុកបាន ក្រដាសស្នាមធ្វើដំណើរសំរាប់ជនភាសខ្លួន ការផ្ទេរកាតសំរាប់ចុះឈ្មោះអ្នកស្រុកក្រៅ សុំពត៌មានពីច្បាប់ឲ្យសេរីភាព document authenticity, notary, រូបថត ពត៌មាននិងការបញ្ជូនបន្តផ្សេងៗ ទៅតាមករណីយនិមួយៗ។

**Services Immigrant Rights & Education Network (SIREN)**
778 N. First St., #202, San Jose, CA 95112
Tel: (408) 286-5680
ការជំនួយរបស់អន្តោប្រវេសន៍ & ពត៌មានទាក់ទង :

អេស្ប៉ាញ៉ូល (408) 286-1698

វៀតណាម (408) 286-1448

Farsi (408) 286-5680 x 108

ចិន (408) 286-5680 x 109

Website: www.siren-bayarea.org

ភាសារ: ចិន Cantonese, Farsi ចិនMandarin អេស្ប៉ាញ៉ូល និង វៀតណាម។

ការបំរើ: ពត៌មានអំពីការចូលសញ្ជាតិ លេខទូរស័ព្ទសំរាប់បញ្ជូនបន្តរ ការជួយដាក់ពាក្យសុំចូលសញ្ជាតិ ការបង្រៀនដល់សហគមពីរបៀប អន្តោប្រវេសន៍ ប្រយោជន៍សាធារណះ ការចូលរួមពីប្រជាពលរដ្ឋ។ ការជួយបង្ហាត់ និងបង្រៀនពីចំណោះសំខាន់សំរាប់ជនអន្តោប្រវេសន៍ និងរឿងរ៉ាវទាក់ទងទាំងឡាយ។

**Santa Clara County District Attorney's Office**
**Consumer Projection Unit**

70 West Hedding Street, West Wing, 4th floor
San Jose, CA 95110
Tel: (408) 792-2880/299-2206
Website: www.santaclara-da.org/consumer.html

ភាសា: Farsi កូរ៉េ អេស្ប៉ាញ៉ូល ចិន Mandarin Taiwanese វៀតណាម លាវ Tagalog បារាំង និង អាឡឺម៉ង់។

ការបំរើ: ទទួលកិច្ចការប្តឹង ដែលទាក់ទងនឹងអន្តោប្រវេសន៍ ក្នុងការលួចបន្លំ។ ជួយឲ្យការដោះស្រាយ ដែលទាក់ទងនឹងសាលារៀន: សិស្ស ឪពុកម្តាយ គ្រូរ អ្នកចាត់ការមើលសាលា អ្នកជិតខាង និងពាណិច្ជកម្មផ្សេងៗ ដែលមានទាក់ទងនឹងសាលារៀន។